ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 04 / 2012
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

002/19-09-2007-ECCC/TC
E1/55

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ២៨ ខែ មីនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៤៣

**រៀបចំដោយ: ឌុច ផារី និង Roger Phillips**

---

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ឌុច ផារី, លោក Roger Phillip |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វ៉េង ហ៊ត់, លោក William SMITH (សហព្រះរាជអាជ្ញារង អន្តរជាតិ), លោក Dale Lysak, |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ (សហមេធាវីជាតិ), លោក Michiel PESTMAN (សហមេធាវីអន្តរជាតិ), លោក Jasper PAUW |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម (សហមេធាវីជាតិ), លោក Michael KARNAVAS (សហមេធាវីអន្តរជាតិ) |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន (សហមេធាវីជាតិ), និងលោក Arthur VERCKEN (សហមេធាវីអន្តរជាតិ) |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ (សហមេធាវីនាំមុខជាតិ), លោកស្រី Elisabeth SIMONNEAU-FORT (សហមេធាវីនាំមុខអន្តរជាតិ), លោកស្រី Lyma NGUYEN, លោកស្រី ម៉ុច សុវណ្ណារី, លោក វ៉ែន ពៅ, លោក គីម ម៉េងឃី, លោក ឡោ ជុនធី, លោក Barnabé NEKUIE |
| សាក្សី៖ កាំង ហ្គេចអ៊ាវ ហៅ ឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោក ឈុន ម៉ារ៉ូហ្សា |
| ផ្សេងៗ៖ កញ្ញា Zuzana KOVALOVA |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃ ពុធ ទី ២៨ ខែ មីនា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.០០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៤ ម៉ោង និង ៤៥ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការតាំងសំណួរដល់សាក្សី កាំង ហ្គេកអ៊ាវ (បន្តពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២) | សហព្រះរាជអាជ្ញា | ៩.០០ | ១៦.០០ |
| សេចក្តីសង្កេតទាក់ទងនឹងការបង្ហាញឯកសារ | មេធាវីការពារក្តី ខៀវ សំផន មេធាវីការពារក្តី នួន ជា សហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ | ៩.១៥ | ៩.២៥ |

| | | | |
|---|---|---|---|
| ការស្នើសុំពេលវេលាបន្ថែម | សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br>អង្គជំនុំជម្រះ | ១០.៣០ | ១០.៥៥ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ១០.៣០<br>១២.០០ | ១០.៣០<br>១២.០០ |
| បញ្ហាមួយចំនួនទាក់ទងនឹងយថាភាពនៃឯកសារ និងសំណើមួយចំនួនរបស់ភាគី | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន<br>មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ១០.៥៥ | ១១.១០ |

**ចក្ខុសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ។

**ការសាកសួរសំណួរដល់សាក្សី កាំង ហ្កេកអ៊ាវ (បន្តពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២)**

សហព្រះរាជអាជ្ញាបន្តការសួរសំណួរដល់សាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ។

**សេចក្តីសម្រេចទាក់ទងនឹងការបង្ហាញឯកសារ**

មេធាវីការពារក្តីជំទាស់ទៅនឹងការអនុវត្តក្នុងការបង្ហាញឯកសារដល់សាក្សី នៅពេលដែលយថាភាពនៃឯកសារនោះមិនទាន់បានបញ្ជាក់ ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ សហព្រះរាជអាជ្ញានិងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី យោងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានប្រកាសកាលពីពេលមុន។ អង្គជំនុំជម្រះបដិសេធទៅលើការជំទាស់ និងរំឭកដល់សហព្រះរាជអាជ្ញាមិនត្រូវស្នើឲ្យសាក្សីធ្វើការពន្យល់អំពីការយល់ឃើញរបស់គាត់លើឯកសារនោះទេ ។

**ការស្នើសុំពេលវេលាបន្ថែម**

អង្គជំនុំជម្រះសម្រេចផ្តល់ពេលវេលាបន្ថែមចំនួនកន្លះថ្ងៃទៀតដល់សហព្រះរាជអាជ្ញា សម្រាប់ការសួរសំណួរដល់សាក្សី ។ មេធាវីការពារក្តី នួន ជា មិនបានជំទាស់ទៅនឹងការស្នើសុំនេះទេ ។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើ (លិខិតលះបង់សិទ្ធិត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ) ។

**បញ្ហាមួយចំនួនទាក់ទងនឹងយថាភាពនៃឯកសារ និងសំណើមួយចំនួនរបស់ភាគី**

បន្ទាប់ពីការសង្កេតរបស់ភាគី អង្គជំនុំជម្រះកត់សម្គាល់ថា ទោះបីជាសំណើមួយចំនួនរបស់ភាគីមិនទាន់ត្រូវបានសម្រេច (ឧទាហរណ៍ ទាក់ទងទៅនឹងយថាភាពនៃឯកសារ) អង្គជំនុំជម្រះកំពុងតែខិតខំដើម្បីឆ្លើយតបទៅនឹងសំណើដែលនៅសេសសល់ ។

Record of Rule 87(3) Proceedings

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/342 | D288 /6.68. 1 | 00329596-00330129 | ឧបសម្ព័ន្ធ ១៖ ការពិនិត្យឡើងវិញ បញ្ជីអ្នកទោសនៅមន្ទីរស ២១ | P | | | |
| E3/12 | 6.3 | 00003136-00003142, 00000758-00000764 00182809-00182814 00224363-00224367 | សេចក្តីសំរេចរបស់គណៈមជ្ឈឹមអំពីបញ្ហាផ្សេងៗមួយចំនួន<br>Decision of central committee on a number of problems<br>Decision of central committee on a number of problems | P | | | |
| E3/1545 | D311 /2 | 00386463-00386474 00391690-00391700 00434948-00434960 | កំណត់ហេតុនៃការស្តាប់ចម្លើយ សាក្សី ឆាំង យុ CHHAN Youk ថ្ងៃទី០៦ តុលា ២០០៩<br>Written Record of Interview of CHHAN Youk ឆាំង យុ<br>Procès verbal d'audition de témoin CHHAN Youk ឆាំង យុ | P | | | |
| E3/811 | D108 /31.4 | 00008502-00008503 00178149-00178150 00314924-00314925 | ឧបសម្ព័ន្ធ០៤:<br>កំណត់ហេតុអង្គប្រជុំជាមួយមន្ទីរ ៧០៣ របស់អង្គការ និង ស-២១<br>Annex 04: Note of Angkar office 703 and S-21 Meeting<br>Annex 04: Note of Angkar office 703 and S-21 Meeting | P | | | |
| E3/801 | 13.33 | 00088911-00088917 00184821-00184823, 00597952-00597960 00322973-00322981 | កំណត់ហេតុនៃការប្រជុំការងារបង្កើនផល សភាពការណ៍ខ្មាំង នឹង សភាពការណ៍បក្ស<br>Note of harvest meeting Enemy and Party Situation<br>Note of harvest meeting Enemy and Party Situation | P | | | |
| E3/763 | D248 /3.3 | 00079279-00079282 00275217-00275220 00623528-00623531 | សេចក្តីណែនាំរបស់គណៈមជ្ឈឹមបក្សកុំម្មុយ នីស្តកម្ពុជា<br>Guidance of Central Committe of the CPK<br>Guidance of Central Committe of the CPK | P | | | |

| **ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖** |
| --- |
| • អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី (ម៉ោង ១០.៣០) និង នួន ជា (ម៉ោង ១២.០០) ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ ។<br>• បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនសាក្សីត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំគាត់មកកាន់សាលសវនាការនៅថ្ងៃទី២៩ ខែ មីនា ឆ្នាំ ២០១២ ឲ្យបានមុនម៉ោង ៩.០០ នាទី ព្រឹក ។<br>• បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២។ |

| **កាលបរិច្ឆេទបន្តសវនាការ៖** |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បត្តិ៍ ទី ២៩ ខែ មីនា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ផារី** **Roger Phillips**